អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

D365/3/1/5

# តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥២)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន**
**ចៅក្រម** Olivier BEAUVALLET
**ចៅក្រម ណី ថុល**
**ចៅក្រម** Kang Jin BAIK
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 13 / 02 / 2018
ម៉ោង (Time/heure): 11:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**(សាធារណៈ:កោសលុប)**

## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី ចុងបណ្តឹងសាទុក្ខ**

សូ មូស្សេនី
Suzana TOMANOVIĆ
Neville SORAB

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ" ដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. សេចក្តីផ្តើម

1. ម្ចាស់បណ្តឹងឧទ្ធរណ៍បានស្នើដល់អង្គបុរេជំនុំជម្រះ ឱ្យបដិសេធដីកាសម្រេច ដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានបដិសេធសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលបានសុំបំពេញកិច្ចស៊ើបសួរលើការចោទប្រកាន់ ពីអំពើហិង្សាផ្លូវភេទនៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ("ដីកាសម្រេចដែលរងការជំទាស់")[2] ដោយផ្អែកលើមូលដ្ឋានដែលថា ការចោទប្រកាន់ទាំងនេះមិនត្រូវបានបញ្ចូល ទៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ជាផ្លូវការទៅលើ [redacted] ("ចុងបណ្តឹងសាទុក្ខ") នោះឡើយ។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត នូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ចោទប្រកាន់ពីការចូលរួមរបស់ចុងបណ្តឹងសាទុក្ខនៅក្នុងអំពើឧក្រិដ្ឋ ដែលរួមមានទាំងការចោទប្រកាន់អំពី អំពើហិង្សាផ្លូវភេទនៅគុកលេខ៨ (ស្រុកកណ្តៀង តំបន់ ៧ ភូមិភាគពាយ័ព្យ) និងបានស្នើសុំចោទប្រកាន់ប្រឆាំងនឹងចុងបណ្តឹងសាទុក្ខ[3]។

---

[1] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក-កសចស ("សំណុំរឿង ០០៤") បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំ បំពេញកិច្ចស៊ើបសួរ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧ ឯកសារ D365/3/1/1 ("បណ្តឹងឧទ្ធរណ៍").

[2] សំណុំរឿង ០០៤, ដីកាសម្រេចលើសំណើរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងគុកលេខ៨ និងអំពើហិង្សាផ្លូវភេទនៅក្នុងស្រុកបាកាន ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D365/3 ("ដីកាសម្រេចដែលរងការជំទាស់") ត្រូវបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧ និងជាភាសាខ្មែរនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៧។

[3] សំណុំរឿង ០០៤, ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញា ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី") ជាពិសេសនៅត្រង់កថាខណ្ឌ ៧២។

3. នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាលើយេនឌ័រ ឬផ្លូវភេទ ដែលរួមមានការចោទប្រកាន់ពីអំពើហឹង្សាលើផ្លូវភេទនៅស្រុកបាកាន (តំបន់២ ភូមិភាគពាយ័ព្យ)[4] ។

4. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងទៅចុងបណ្ដឹងសាទុក្ខថា គាត់ត្រូវបានចោទប្រកាន់ពីបទនានា ដូចជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទៅលើអ្នកជម្លៀសមកពីភូមិភាគបូព៌ា និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំង/ការធ្វើការក្នុងស្ថានភាពអមនុស្សធម៌) នៅគុកលេខ៨[5]។

5. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ដោយបានកត់សម្គាល់ថាមាន “ភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា ការរំលោភផ្លូវភេទ [...] បានប្រព្រឹត្តឡើងមកលើនារីខ្មែរក្រោម និង “អ្នកជម្លៀសមកពីភូមិភាគបូព៌ា” នៅស្រុកបាកាន” ប៉ុន្តែ “មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា [ចុងបណ្ដឹងសាទុក្ខ] អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះទេ”[6] សហចៅក្រមស៊ើបអង្កេតអន្តរ

---

[4] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D191 (“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ”), ជាពិសេសនៅត្រង់កថាខណ្ឌ ៧។

[5] សំណុំរឿង ០០៤ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D281 ទំព័រ ៥, ១២ ដល់១៣, ១៥ ដល់១៦។

[6] សំណុំរឿង ០០៤ សំណើសុំមតិយោបល់ទាក់ទងនឹង ការចោទប្រកាន់អំពីអង្គហេតុ ដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ D302 (“សំណើសុំមតិយោបល់”) កថាខណ្ឌ ៣។

ជាតិ បន្ទាប់ពីបានស្តាប់ភាគីនានារួចមក[7] បានសម្រេចបន្តកិច្ចស៊ើបអង្កេតទៅលើឧក្រិដ្ឋកម្មទាំងអស់នេះ[8]។

6. នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបន្ថែមបទចោទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍ ទៅលើខ្មែរក្រោម និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌) នៅទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំ នៅក្នុងស្រុកបាកាន[9]។

7. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ភាគីអំពីការបញ្ចប់កិច្ចស៊ើបសួរ ហើយ[10] នៅថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៧ បានពន្យាពេល១៥ថ្ងៃ បន្ថែមសម្រាប់ការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ រហូតដល់ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧[11]។

8. នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរដោយស្នើសុំឱ្យស៊ើបអង្កេតទៅលើការចោទប្រកាន់ពីឧក្រិដ្ឋកម្មនានា រួមទាំងអំពើហិង្សា

---

[7] *See* សំណុំរឿង ០០៤ សារណារបស់ [redacted] ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុ ដែលនឹងមិនស៊ើបអង្កេតបន្ថែមទៀត ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ កថាខណ្ឌ D302/1។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សុំយោបល់ទាក់ទងនឹងការចោទប្រកាន់ ពីអង្គហេតុដែលមិនស៊ើបអង្កេតបន្ថែម ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ D302/2។

[8] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការផ្អាក កិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ D302/3 ("សេចក្តីជូនដំណឹងអំពីការផ្អាកបណ្តោះអាសន្ន") កថាខណ្ឌ ៣២។

[9] សំណុំរឿង ០០៤, ឧបសម្ព័ន្ធ៖ សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង [redacted] ដែលបានកែប្រែ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D350.1 ("សេចក្តីជូនដំណឹងអំពីបទចោទ ដែលបានកែប្រែ") ទំព័រ ២,៥, ៩ (មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រៃ ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ និងទីតាំងសម្លាប់មនុស្សវត្តចន្ទរង្សី)។

[10] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ [redacted] ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ D358។

[11] សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើរបស់ [redacted] សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D361/4។

ផ្លូវភេទ ដែលបានប្រព្រឹត្តនៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ("សំណើសុំបំពេញកិច្ចស៊ើបសួរ")[12]។

9. នៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាសម្រេចដែលរងការជំទាស់ បដិសេធនូវសំណើសុំបំពេញកិច្ចស៊ើបសួរលើការចោទប្រកាន់ពីអំពើហិង្សាផ្លូវភេទនៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន។

10. នៅថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍[13] ហើយនៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧ បានដាក់បណ្តឹងឧទ្ធរណ៍របស់គាត់។ សហមេធាវីការពារក្តីអ្នកឆ្លើយតប ("សហមេធាវី") បានដាក់ចម្លើយតបរបស់ពួកគេ នៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧[14] ហើយសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ការឆ្លើយតបនៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧[15]។

---

[12] សំណុំរឿង ០០៤ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹង គុកលេខ៨ នៅស្រុកកណ្តៀង និងអំពើហិង្សាផ្លូវភេទនៅស្រុកបាកាន ខេត្តពោធិ៍សាត់ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D365 ("សំណើសុំបំពេញកិច្ចស៊ើបសួរ")។

[13] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងសេចក្តីសម្រេច លើសំណើសុំបំពេញកិច្ចស៊ើបសួរ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៧ ឯកសារ D365/3/1។

[14] សំណុំរឿង ០០៤ ចម្លើយតបរបស់ [redacted] ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើ សំណើសុំបំពេញកិច្ចស៊ើបសួរ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D365/3/1/3 ("ចម្លើយតប") ត្រូវបានជូនដំណឹងជាភាសាអង់គ្លេសនិងភាសាខ្មែរ នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៧។ *សូមមើលផងដែរ* សំណុំរឿង ០០៤ សំណើបន្ទាន់សុំការអនុញ្ញាតដើម្បីដាក់ចម្លើយតបរបស់ [redacted] ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំ បំពេញកិច្ចស៊ើបសួរ តែមួយភាសា ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D365/3/1/2។

[15] សំណុំរឿង ០០៤ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ [redacted] ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចលើ សំណើសុំបំពេញកិច្ចស៊ើបសួរ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឯកសារ D365/3/1/4 ("ការឆ្លើយតប") ត្រូវបានជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរ នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧។

## III. ភាពអាចទទួលយកបាន

11. បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ អនុលោមតាមវិធាន ៧៤(២) និង ៧៥(៣) នៃវិធានផ្ទៃក្នុង[16]។ សហមេធាវីបានលើកឡើងថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេ ព្រោះសហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបង្ហាញពីកំហុសអង្គច្បាប់ ឬកំហុសអង្គហេតុណាមួយ ដែលជាកត្តាកំណត់យ៉ាងសំខាន់នៃការអនុវត្តឆន្ទានុសិទ្ធិ របស់សហចៅក្រមស៊ើបអង្កេត[17]។

12. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អនុលោមតាមវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង "សហព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ទៅលើដីកាសម្រេចទាំងអស់របស់សហចៅក្រមស៊ើបអង្កេត"។ អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ និងសារណាបណ្តឹងឧទ្ធរណ៍ ត្រូវបានដាក់អនុលោមទៅតាមពេលវេលាកំណត់ ដូចមានចែងក្នុងមាត្រា ៧៥(១) និង(៣) នៃវិធានផ្ទៃក្នុង ហើយសម្រេចបដិសេធទឡ្ហីករណ៍ ដែលបានលើកឡើងនៅក្នុងចម្លើយតប ដែលទាក់ទងនឹងបទដ្ឋាននៃការត្រួតពិនិត្យបណ្តឹងឧទ្ធរណ៍ មិនមែនទាក់ទងនឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នោះឡើយ។

13. ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន។

## IV. បទដ្ឋាននៃការត្រួតពិនិត្យ

14. អនុលោមតាមយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ[18] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអាចត្រូវបានច្រានចោលប្រសិនបើដីកាសម្រេចនោះ (ក) ផ្អែកលើកំហុសអង្គច្បាប់ ដែលនាំឲ្យមោឃភាពដីកាសម្រេចនោះ (ខ) ផ្អែកលើកំហុសអង្គហេតុដែលនាំឲ្យមានកំហុសក្នុងការស្វែងរកយុត្តិធម៌ ឬ (គ) មិនយុត្តិធម៌ ឬមិនសមហេតុផលដែលនាំឲ្យកើតមានការបំពានលើឆន្ទានុសិទ្ធិ

---

[16] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១។

[17] ចម្លើយតប កថាខណ្ឌ ១៥ ដល់១៩។

[18] *សូមមើលជាឧទាហរណ៍* សំណុំរឿង ០០៤/០២/០៧-០៩-២០០៩-អវតក-កសចស ("សំណុំរឿង ០០៤/២") (អបជ ៣៥) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេច លើសំណើរសុំបំពេញកិច្ចស៊ើបសួរលើកទី១២ របស់ [redacted] ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D320/1/1/4 ("សេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២") កថាខណ្ឌ ៥

*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹងអំពើហិង្សាផ្លូវភេទនៅ គុកលេខ៨ និងស្រុកបាកាន។*

របស់ចៅក្រម។ លក្ខណៈវិនិច្ឆ័យទាំងអស់នេះ ត្រូវអនុវត្តចំពោះអង្គសេចក្តីនៃដីកាសម្រេចដែលរងការជំទាស់។

15. ដើម្បីឱ្យអង្គបុរេជំនុំជម្រះអាចច្រានចោលការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវតែបង្ហាញថា ដីកាសម្រេចដែលរងការជំទាស់គឺ (១) ផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើច្បាប់ជាធរមាន (២) ផ្អែកលើការសន្និដ្ឋានលើអង្គហេតុដែលពុំត្រឹមត្រូវពិតប្រាកដ និង/ឬ(៣) មិនយុត្តិធម៌ ឬមិនសមហេតុផលដែលនាំឱ្យកើតមាន ការបំពានលើឆន្ទានុសិទ្ធិរបស់ សហចៅក្រមស៊ើបអង្កេត។ ពុំមែនរាល់កំហុសទាំងអស់នឹងបណ្តាលឱ្យ អង្គបុរេជំនុំជម្រះច្រានចោលដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនោះទេ។ កំហុសនោះត្រូវតែជាកត្តាកំណត់សំខាន់ក្នុងការអនុវត្តឆន្ទានុសិទ្ធិដែលបណ្តាលឱ្យមានការសម្រេចដែលរកការជំទាស់នេះ[19]។

## V. ច្បាប់ជាធរមាន

16. វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង បានចែងពីសិទ្ធិរបស់ភាគី ក្នុងការស្នើសុំបំពេញកិច្ចស៊ើបសួរ៖

> "នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រម សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឱ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ ។ ដីកាបដិសេធនេះ ត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី ។ ដីកាបដិសេធនេះបើកផ្លូវប្តឹងឧទ្ធរណ៍។"

17. អង្គបុរេជំនុំជម្រះបានសម្រេចថា ត្រូវបំពេញបាននូវលក្ខខណ្ឌត្រួតពីរ ដើម្បីអាចឱ្យសហចៅក្រមស៊ើបអង្កេតយល់ព្រមតាមសំណើសុំ៖ (១) លក្ខខណ្ឌស្តីពីភាពច្បាស់លាស់ និង (២) លក្ខខណ្ឌស្តីពីភាពពាក់ព័ន្ធ *បឋម*។ ភាគីដែលដាក់សំណើសុំ តាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ត្រូវកំណត់ឱ្យ

---

[19] *សូមមើលជាឧទាហរណ៍* សេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២ កថាខណ្ឌ ១០។

ច្បាស់នូវការស្នើសុំបំពេញកិច្ចស៊ើបសួរ និងរៀបរាប់មូលហេតុដែលភាគីស្នើសុំយល់ឃើញថា មានភាពចាំបាច់សម្រាប់ដឹកនាំការស៊ើបអង្កេត[20]។

## VI. អង្គសេចក្តី

### ក. សារណា

18. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងអង្គច្បាប់ ក្នុងការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ លើការចោទប្រកាន់ពីអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ដោយផ្អែកលើមូលដ្ឋានដែលថា ការចោទប្រកាន់ទាំងនេះមិនត្រូវបានរួមបញ្ចូល នៅក្នុងឧក្រិដ្ឋកម្មដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ជាផ្លូវការទៅលើចុងបណ្តឹងសាទុក្ខនោះ[21]។

19. សហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់ជាដំបូងថា ការសម្រេចនៅក្នុងដីកាដំណោះស្រាយ សំណុំរឿង ០០៤/១ ដែលដីកាសម្រេចដែលរងការជំទាស់ពឹងផ្អែកលើ ដែលបញ្ជាក់ថាអង្គហេតុដែលមិនត្រូវបាន "ចោទប្រកាន់" មិនអាចត្រូវបញ្ជូនទៅជំនុំជម្រះនោះ គឺមិនត្រឹមត្រូវតាមផ្លូវច្បាប់ឡើយ[22] ។ គាត់បានចង្អុលបង្ហាញទៅរកការសម្រេចរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿង ០០២ ដែលថា ប្រសិនបើពួកគាត់ "មិនអាចនឹងធ្វើការបញ្ជូនបុគ្គលណាមួយទៅជំនុំជម្រះ ចំពោះអង្គហេតុណាដែលបុគ្គលនោះ មិនត្រូវបានដាក់ឲ្យឋិតក្រោមការពិនិត្យជាមុននោះទេ" សហចៅក្រមស៊ើបអង្កេត "ត្រូវវិនិច្ឆ័យលើអង្គហេតុទាំងអស់ ដែលត្រូវបានប្តឹងដោយត្រឹមត្រូវតាមនីតិវិធីច្បាប់។ ក្នុងនោះសហចៅក្រមស៊ើបអង្កេត អាចនឹងចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកា

---

[20] *សូមមើលជាឧទាហរណ៍* សេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២ កថាខណ្ឌ ១៣។

[21] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២, ៩ *យោងទៅរក* ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៤០, ៥០។

[22] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១០, ១១ *យោងទៅរក* សំណុំរឿង ០០៤/០១/០៧-០៩-២០០៩-អវតក-កសចស ("សំណុំរឿង ០០៤/១") ដីកាដំណោះស្រាយ(សំអាងហេតុ) ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ ២៤៥។ សំណុំរឿង ០០៤/០១ (អបជ៥០ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ(សំអាងហេតុ) ថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/1 កថាខណ្ឌ ១១ ដល់២២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

លើកលែងការចោទប្រកាន់"[23]។ តាមទស្សនៈរបស់គាត់ យុត្តិសាស្ត្រមួយនេះគ្រាន់តែអះអាងគាំទ្រទៅលើគោលការណ៍ដែលថាបុគ្គលម្នាក់ មិនអាចបញ្ជូនទៅជំនុំជម្រះបានឡើយ លុះត្រាតែសហចៅក្រមស៊ើបអង្កេត បានទទួលប្រកបដោយសុពលភាពតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលដីកាសន្និដ្ឋាននេះមានគោលបំណង ដើម្បីជូនដំណឹងដល់ជនសង្ស័យ ឬជនជាប់ចោទអំពីលក្ខណៈ និងមូលហេតុនៃបទចោទ ប្រឆាំងរូបគាត់[24]។ កាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ដើម្បីធ្វើនូវការរកឃើញមួយដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយអំពីការចោទប្រកាន់ទាំងអស់ នឹងត្រូវបញ្ចប់ ប្រសិនបើសហចៅក្រមស៊ើបអង្កេត គ្រាន់តែជ្រើសរើសធ្វើមិនដឹងមិនឮអំពីអង្គហេតុ ដោយការមិនចោទប្រកាន់ពីបទចោទទាំងអស់នោះ[25]។

20. សហព្រះរាជអាជ្ញាអន្តរជាតិក៏បានអះអាងផងដែរថា ការសម្រេចថាអង្គហេតុដែលមិនត្រូវបានចោទប្រកាន់ មិនអាចត្រូវបានពិចារណា សម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ គឺជាការផ្ទុយពីយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ដែលបានបញ្ជាក់យ៉ាងច្បាស់លាស់ ដោយមិនបានយោងទៅរកដំណើរការនៃការចោទប្រកាន់ជាផ្លូវការថាដីកាដំណោះស្រាយត្រូវតែមានការសម្រេចទៅលើអង្គហេតុទាំងអស់ ដែលសហចៅក្រមស៊ើបអង្កេត បានទទួលដោយត្រឹមត្រូវ[26]។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានសង្កត់ធ្ងន់ផងទៅលើភាពផ្ទុយគ្នាអំពីសេចក្តីថ្លែងការណ៍ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ HARMON នៅក្នុងសំណុំរឿង ០០៤/១ និង០០៤/២ ដែលថា បញ្ហានៃយុត្តាធិ

[23] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២ *យោងទៅរក* សំណុំរឿង ០០/១៩-០៩-២០០៧-អវតក-កសចស ("សំណុំរឿង ០០២") ដីកាសម្រេចលើសំណើ របស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើការបំភ្លឺ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D198/1 ("ដីកាសម្រេចសំណុំរឿង ០០២") កថាខណ្ឌ ១០។

[24] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៣ ដល់១៥ យោងទៅរកផងដែរ មាត្រា ៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

[25] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៦។

[26] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៨ *យោងទៅរក* សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ02) សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណី [redacted] ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 (" សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សំណុំរឿង [redacted] ") កថាខណ្ឌ ២៩, ៣២ ដល់៣៩។



E.C.C.C. • C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉ

ការលើរូបបុគ្គល នឹងត្រូវសម្រេចនៅពេលបញ្ចប់កិច្ចស៊ើបសួរ ដោយ ពិនិត្យមើលភស្តុតាងទាំងអស់ដែលប្រមូលបាន[27]។

21. ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ការបដិសេធមិនស៊ើបអង្កេតលើការចោទប្រកាន់ ដែលមិនត្រូវបានចោទប្រកាន់ជាផ្លូវការ គឺជាការរំលោភបំពានទៅលើភាពកិច្ចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ តាមមាត្រា ៥៥(២) នៃវិធានផ្ទៃក្នុង ដែលត្រូវស៊ើបអង្កេតលើអង្គហេតុទាំងអស់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម រួមទាំងអំពើហិង្សាលើផ្លូវភេទនៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន[28]។ សហព្រះរាជអាជ្ញាអន្តរជាតិបានចង្អុលទៅរកយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ[29] ហើយអះអាងថា វិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង ចែងពីវិធានការដើម្បីកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ តាមរយៈការដកចេញនូវអង្គហេតុ ប៉ុន្តែអាចធ្វើបានតែនៅពេលបញ្ចប់កិច្ចស៊ើបអង្កេតប៉ុណ្ណោះ គឺបន្ទាប់ពីបានស្តាប់ភាគីនានា និងធ្វើឡើងតាមរយៈសេចក្តីសម្រេច ដែលអាចប្តឹងឧទ្ធរណ៍បានប៉ុណ្ណោះ[30]។ នៅក្នុងករណីបច្ចុប្បន្ន ការចោទប្រកាន់ពីអំពើហិង្សាលើផ្លូវភេទនៅក្នុងស្រុកបាកាន ត្រូវបានយោងតាមករណីនីតិវិធីនៃវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង ហើយមិនទាន់ត្រូវបានបញ្ចូលជាចុងក្រោយ ទៅក្នុងការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរនោះឡើយ[31]។ ការដកចេញនូវអង្គហេតុ ដោយមិនមានសេចក្តីសម្រេចដោយមានសំអាងហេតុ តាមរយៈការមិនចោទប្រកាន់ជាផ្លូវការនោះ នឹងបង្កើតបានជាយុត្តិសាស្ត្រមួយដែលមានផលវិបាកគួរឲ្យបារម្ភ ជាពិសេសនៅពេលដែលទាក់ទងនឹងឧក្រិដ្ឋកម្មនៃអំពើហិង្សាផ្លូវភេទ ដែលមិនសូវមានការរាយការណ៍ឲ្យបានពេញលេញ[32]។

---

[27] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២១ *យោងទៅរក* សំណុំរឿង ០០៤/១ សំណើសុំដាក់សារណា ថាតើ [redacted] គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" និង/ឬស្ថិតក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D251, កថាខណ្ឌ ៥។ សំណុំរឿង ០០៤/២ ដីកាសម្រេចលើញត្តិរបស់ [redacted] ស្នើសុំមោឃភាពកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D185/1 កថាខណ្ឌ ២៨។

[28] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៨, ៩, ២២ ដល់២៤ *យោងទៅរក* ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី កថាខណ្ឌ ៧២។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម, កថាខណ្ឌ 7។

[29] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៤ និងជើងទំព័រ ៤៤។

[30] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៥។

[31] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៦។

[32] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៧ ដល់២៨។

22. សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងបន្ថែមទៀតថា ដីកាសម្រេចដែលរងការជំទាស់ មានតម្លៃស្មើទៅនឹងការបដិសេធសិទ្ធិទទួលបានការជំនុំជម្រះរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយសារតែគាត់មិនត្រូវបានអញ្ជើញឱ្យដាក់សារណាអំពីឧក្រិដ្ឋកម្មណាមួយ ដែលចុងបណ្តឹងសាទុក្ខត្រូវបានចោទប្រកាន់[33] និងអំពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍របស់គាត់[34]។ សហព្រះរាជអាជ្ញាអន្តរជាតិបានគូសបញ្ជាក់ថា មេធាវីការពារក្តីត្រូវបានជូនដំណឹងយ៉ាងច្បាស់លាស់ អំពីអង្គហេតុដែលអាចនាំទៅដល់ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ហើយជាក់ស្តែងបានលើកឡើងនូវទឡ្ហីករណ៍ផ្លូវច្បាប់ជាក់លាក់ទាក់ទងនឹងការចោទប្រកាន់ពីអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ក្នុងការឆ្លើយតបចំពោះ សំណើសុំបំពេញកិច្ចស៊ើបសួរ និងតាមរយៈសំណើសុំមោឃភាព[35]។

23. សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងជាចុងក្រោយថា បណ្តឹងឧទ្ធរណ៍គួរត្រូវបានដោះស្រាយមុនពេលបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ហើយគួរត្រូវធ្វើឡើងជាសាធារណៈ[36]។

24. សហមេធាវីបានឆ្លើយតបថា បណ្តឹងឧទ្ធរណ៍ដំណើរការដោយផ្អែកលើ ការសន្មតដែលខុសឆ្គងមួយចំនួន ហើយគួរត្រូវបានបដិសេធចោល[37]។ សហមេធាវីបានអះអាងជាពិសេសថា សហព្រះរាជអាជ្ញាអន្តរជាតិ មានកំហុសឆ្គងក្នុងការអះអាងថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម គឺមានបំណងដើម្បីជូនដំណឹងដល់ជនសង្ស័យឬជនជាប់ចោទ អំពីលក្ខណៈនៃការចោទប្រកាន់ប្រឆាំងរូបគាត់។ តាមពិត ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម គឺគ្រាន់តែបង្ហាញពីទ្រឹស្តីនៃសំណុំរឿងបឋមរបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ[38]។ សហចៅក្រមស៊ើបអង្កេតឯនោះទេ ដែលជាអ្នកជូនដំណឹងដល់ជនសង្ស័យ ឬជនជាប់ចោទ អំពីការចោទប្រកាន់ប្រឆាំងរូបគាត់ បន្ទាប់ពីបានធ្វើការស៊ើបអង្កេត

[33] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩។

[34] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២, ២៩ ដល់៣០។

[35] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣១ ដល់៣៥។

[36] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៦ ដល់៣៧។

[37] ចម្លើយតប ទំព័រ ១ និង កថាខណ្ឌ ២១ ដល់២២។

[38] ចម្លើយតប កថាខណ្ឌ ២៣ ដល់២៤។

យ៉ាងលម្អិត តាមរយៈដំណើរការចោទប្រកាន់ និងការកែប្រែបទចោទនៅពេលបន្ទាប់ ដែលជាការគូសព្រាងអំពីទស្សនៈបច្ចុប្បន្ន របស់សហចៅក្រមស៊ើបអង្កេតចំពោះសំណុំរឿង និងផ្លាស់ប្តូរស្ថានភាព និងលទ្ធភាពរបស់ជនសង្ស័យ ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី[39]។ ហេតុដូច្នេះសហមេធាវីបានអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិ មិនត្រូវបានអនុញ្ញាតឲ្យព្យាយាមធ្វើការចោទប្រកាន់ចំពោះបទចោទផ្សេងទៀតក្រៅពីបទចោទនានាដែលមានចែងនៅក្នុងសេចក្តីជូនដំណឹងចុងក្រោយអំពីបទចោទដែលបានកែប្រែនោះឡើយ[40]។ សហមេធាវីបានសង្កត់ធ្ងន់ថា គាត់មានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ចំពោះដីកាសម្រេចកែប្រែបទចោទ តែគាត់សម្រេចជ្រើសរើសមិនប្តឹងឧទ្ធរណ៍ទៅវិញ[41]។

25. សហមេធាវីអះអាងបន្ថែមទៀតថា មិនមានភស្តុតាងដែលថា ការចោទប្រកាន់ពីអំពើហិង្សាផ្លូវភេទនៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ត្រូវបានទុកចោល មិនស៊ើបអង្កេតនោះឡើយ[42]។ សហមេធាវីបានចង្អុលបង្ហាញជាពិសេស អំពីការដឹងឮរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលថាសំណុំរឿងមានរួចហើយនូវឯកសារសម្ភារៈ ទាក់ទងអំពើហិង្សាលើផ្លូវភេទនៅក្នុងស្រុកបាកាន[43] ហើយបានឆ្លើយតបទាក់ទងអង្គហេតុ ដែលត្រូវបានចោទប្រកាន់ ថាមិនត្រូវស៊ើបអង្កេតបន្តទៀតឡើយ[44]។ ហេតុដូច្នេះមិនមានសំអាងហេតុដែលជឿថា សហចៅក្រមស៊ើបអង្កេតមិនបានបញ្ចប់កិច្ចស៊ើបអង្កេតរបស់គាត់ទៅលើការចោទប្រកាន់ពីអំពើហិង្សាផ្លូវភេទនៅក្នុងស្រុកបាកាននោះទេ[45]។

---

[39] ចម្លើយតប កថាខណ្ឌ ២៤ ដល់២៦។

[40] ចម្លើយតប កថាខណ្ឌ ២៧ *យោងទៅរក* សំណុំរឿង ០០៤ ឧបសម្ព័ន្ធ៖ សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង [redacted] ដែលបានកែប្រែ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D350.1។

[41] ចម្លើយតប កថាខណ្ឌ ២៦ *យោងទៅរក* សំណុំរឿង ០០៤ ដីកាសម្រេចកែប្រែបទចោទប្រឆាំង [redacted] ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ ឯកសារ D350។

[42] ចម្លើយតប កថាខណ្ឌ ២៩។

[43] ចម្លើយតប កថាខណ្ឌ ៣០ *យោងទៅរក* សំណើសុំបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ ១៥។

[44] ចម្លើយតប កថាខណ្ឌ ៣១ ដល់៣៣ *យោងទៅរក* សំណើសុំមតិយោបល់ កថាខណ្ឌ ៣។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សុំយោបល់ទាក់ទងនឹងការចោទប្រកាន់ពីអង្គហេតុដែលមិនស៊ើបអង្កេតបន្ថែម ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ D302/2 កថាខណ្ឌ ២៣។

[45] ចម្លើយតប កថាខណ្ឌ ៣៣។

26. សហមេធាវីអះអាងជាពិសេសថា សហព្រះរាជអាជ្ញាអន្តរជាតិដាក់បញ្ចូលគ្នា នូវការបន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ជាមួយការលើកលែងបទចោទ បន្ទាប់ពីមានការស៊ើបអង្កេតត្រឹមត្រូវ ដែលដូច្នេះហើយធ្វើឱ្យសារណារបស់គាត់ ទាក់ទងវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង មិនសមស្របទាល់តែសោះ[46]។ តាមពិតទៅសហចៅក្រមស៊ើបអង្កេត មានឆន្ទានុសិទ្ធិ ក្នុងការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬលើកលែងបទចោទ តាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង ហើយមិនមានជាប់កាតព្វកិច្ចជាមួយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិនោះឡើយ[47]។ ការពិតដែលថាចុងបណ្តឹងសាទុក្ខមិនត្រូវបានជូនដំណឹងអំពីបទចោទទាក់ទងនឹងការចោទប្រកាន់ទាំងអស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម គឺគ្រាន់តែជាការចង្អុលបង្ហាញថា មិនបានបំពេញតាមលក្ខខណ្ឌតម្រូវអប្បបរមានៃភស្តុតាង សម្រាប់ការចោទប្រកាន់តែប៉ុណ្ណោះ[48] គឺមិនមែនថា លក្ខខណ្ឌយុត្តាធិការដែលលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបានផ្លាស់ប្តូរនោះឡើយ[49]។

27. ជាចុងក្រោយសហមេធាវីបានលើកឡើងថា ការអះអាងដែលថាសហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចត្រូវផ្តល់សំអាងហេតុ សម្រាប់សេចក្តីសម្រេចចោទប្រកាន់របស់ខ្លួន មុនពេលចេញដីកាដំណោះស្រាយនោះ គឺមានភាពឆាប់រហ័សពេក និងមានកំហុសឆ្គង ដោយសារតែមិនមានការបញ្ជាក់ណាមួយដែលថា សហចៅក្រមស៊ើបអង្កេតបានធ្វើការសម្រេចកំណត់ដោយពេញលេញទៅលើការចោទប្រកាន់នានា ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[50]។ ហេតុដូច្នេះមិនមានការបដិសេធសិទ្ធិរបស់សហព្រះរាជអាជ្ញា ក្នុងការលើកមកបើកសវនាការ ឬសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍នោះទេ[51]។

28. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងឡើងវិញ ពីទឡ្ហីករណ៍របស់គាត់ នៅក្នុងការឆ្លើយតប ហើយបានគូសបញ្ជាក់ថា សំណើសុំបំពេញកិច្ចស៊ើបសួរ ត្រូវបានបដិសេធដោយសារតែ ចុងបណ្តឹងសា

---

[46] ចម្លើយតប កថាខណ្ឌ ៣៤ ដល់៣៩។

[47] ចម្លើយតប កថាខណ្ឌ ៣៦។

[48] ចម្លើយតប កថាខណ្ឌ ៣៧។

[49] ចម្លើយតប កថាខណ្ឌ ៣៥។

[50] ចម្លើយតប កថាខណ្ឌ ៤០ ដល់៤១។

[51] ចម្លើយតប កថាខណ្ឌ ៤១ ដល់៤២។

ទុក្ខមិនត្រូវបានចោទប្រកាន់លើបទចោទ ហើយថាដីកាសម្រេចដែលរងការជំទាស់ មិនមានការពិចារណាណាផ្សេង ទាក់ទងនឹងភស្តុតាងដែលស្នើសុំលើកយកមកបង្ហាញ[52]។ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងម្តងទៀតថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់ ដោយសារតែនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលរបស់កម្ពុជា ចៅក្រមស៊ើបអង្កេតមិនមានឆន្ទានុសិទ្ធិ ក្នុងការទុកចោលបទចោទ តាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន និងកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបអង្កេត ដោយមិនមានសេចក្តីសម្រេចដោយមានសំអាងហេតុនោះឡើយ[53]។ តាមពិតទៅមិនមានលក្ខខណ្ឌតម្រូវនៅក្នុងវិធានផ្ទៃក្នុង ឬយុត្តិសាស្ត្រដែលថា សំណើសុំបំពេញកិច្ចស៊ើបសួរ ចាំបាច់ត្រូវតែទាក់ទងជាមួយឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះឡើយ[54]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងបន្ថែមទៀតថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម មានតួនាទីជាឯកសារជូនដំណឹង នៅក្នុងដំណាក់កាលស៊ើបអង្កេត ដែលគាត់អាចព្យាយាមឲ្យមានការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចំពោះការចោទប្រកាន់ណាមួយ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ហើយថាចុងបណ្តឹងសាទុក្ខតែងតែដំណើរការ ដោយការដឹងច្បាស់ថា គាត់អាចត្រូវបានបញ្ជូនទៅជំនុំជម្រះ ពីបទឧក្រិដ្ឋកម្មទាំងអស់នោះ ដោយមិនគិតថាតើ គាត់ត្រូវបានចោទប្រកាន់ដែរឬអត់ ពីបទឧក្រិដ្ឋទាំងអស់នោះទេ[55]។

29. សហព្រះរាជអាជ្ញាអន្តរជាតិក៏បានសង្កត់ធ្ងន់ផងដែរថា សេចក្តីសម្រេចចោទប្រកាន់ គឺគ្រាន់តែជាសេចក្តីសម្រេចបណ្តោះអាសន្នប៉ុណ្ណោះ ហើយការចោទប្រកាន់អាចត្រូវបានលើកលែង អនុលោមតាមវិធាន ៦៦ស្ទួន និងវិធាន ៦៧ នៃវិធានផ្ទៃក្នុង ដែលមុនពេលមានការលើកលែង បទចោទទាំងអស់នោះចាំបាច់ត្រូវតែមានការស៊ើបអង្កេតឲ្យបានត្រឹមត្រូវ[56]។ ហេតុដូច្នេះដីកាសម្រេចដែលរងការជំទាស់ គឺជាការកាត់បន្ថយជាក់ស្តែងទៅលើវិសាលភាពនៃកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ[57]

---

[52] ការឆ្លើយតប កថាខណ្ឌ ១៤។

[53] ការឆ្លើយតប កថាខណ្ឌ ២។

[54] ការឆ្លើយតប កថាខណ្ឌ ៤។

[55] ការឆ្លើយតប កថាខណ្ឌ ៥ ដល់៩។

[56] ការឆ្លើយតប កថាខណ្ឌ ១១ ដល់១២។ *សូមមើលផងដែរ* កថាខណ្ឌ ១៦។

[57] ការឆ្លើយតប កថាខណ្ឌ ១៣។

។ ជាចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់ទៅនឹងការអះអាងដែលថាគាត់អាចប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចកែប្រែបទចោទ ដែលមិនមានសំអាងហេតុ ដែលមិនមែនជាដីកាសម្រេចស្ថាពរ ឬថាគាត់អាចប្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយនោះ គឺគ្រាន់តែជាការទាយស្មានសុទ្ធសាធ[58]។

## ខ. ការពិភាក្សា

30. អង្គបុរេជំនុំជម្រះនឹងពិចារណាទៅលើ៖ (១) ថាតើបណ្តឹងឧទ្ធរណ៍អាចត្រូវបានសម្រេច មុនពេលចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ តាមវិធាន ៦៦(៤) ហើយអាចធ្វើឡើងជាសាធារណៈដែរឬទេ (២) ថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងដែរឬយ៉ាងណា ក្នុងការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ដោយផ្អែកលើមូលដ្ឋានដែលថា ឧក្រិដ្ឋកម្មដែលត្រូវរងការចោទ មិនត្រូវបានចោទប្រកាន់ និង (៣) ថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរំលោភលើកាតព្វកិច្ចរបស់គាត់ ក្នុងការស៊ើបអង្កេតទៅលើអង្គហេតុទាំងអស់ ដែលគាត់បានទទួលដោយសុពលភាពដែរឬទេ។

### ១. <u>បញ្ហាបឋម</u>

31. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា បណ្តឹងឧទ្ធរណ៍គួរត្រូវបានសម្រេច មុនពេលបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ហើយគួរធ្វើឡើងជាសាធារណៈ[59]។

32. ទាក់ទងនឹងការបញ្ជូនសំណុំរឿងទៅពិនិត្យ យោងតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេត "ត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅសហព្រះរាជអាជ្ញា" ដើម្បីឲ្យសហព្រះរាជអាជ្ញាអាចចេញដីកាសន្និដ្ឋានស្ថាពរ បន្ទាប់ពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ត្រូវបាន "លើកយកមកធ្វើសវនាការ"។ អង្គបុរេជំនុំជម្រះពិចារណាថា ភាពច្បាស់លាស់ផ្នែកនីតិវិធីតម្រូវថា បណ្តឹងឧទ្ធរណ៍បែបនេះ មិនគ្រាន់តែត្រូវបានលើកយកមកធ្វើសវនាការប៉ុណ្ណោះទេ ថែមទាំងត្រូវបានសម្រេចទៀតផង មុនពេល

[58] ការឆ្លើយតប កថាខណ្ឌ ១៧ ដល់១៩។

[59] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៦ ដល់៣៧។

ចេញដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា។ នៅក្នុងករណីណាក៏ដោយ អង្គបុរេជំនុំជម្រះយល់ឃើញថា គឺជាការទាយស្មាននៅពេលនេះ បើធ្វើការពិចារណាថា សហចៅក្រមស៊ើបអង្កេតធ្វើការបកស្រាយផ្សេង ទៅលើវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ហើយអង្គបុរេជំនុំជម្រះសូមរំឮកថា មិនទាន់មានដីកាសន្និដ្ឋានស្ថាពរនៅឡើយទេ ដែលធ្វើឱ្យសំណើសុំនេះទៅជាអាសារឥតការ។

33. ចំពោះបញ្ហាធ្វើឡើងជាសាធារណៈនោះ អង្គបុរេជំនុំជម្រះសូមរំឮកថា អនុលោមតាមវិធាន ៧៨ នៃវិធានផ្ទៃក្នុង ចាំបាច់ត្រូវតែផ្សព្វផ្សាយទាំងស្រុង "រាល់សេចក្តីសម្រេចដែលមានសំលេងគាំទ្រគ្រប់គ្រាន់ និងរាល់សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រគ្រប់គ្រាន់របស់អង្គបុរេជំនុំជម្រះ [...] លើកលែងតែ [...] ការបោះពុម្ពផ្សាយនោះអាចប៉ះពាល់ដល់ផលប្រយោជន៍ នៃការអង្កេតបឋម ឬការស៊ើបសួរ"។ អង្គបុរេជំនុំជម្រះយល់ឃើញថា ជាការត្រឹមត្រូវក្នុងការផ្សព្វផ្សាយសាលដីកាលើបណ្តឹងឧទ្ធរណ៍ជាសំណៅសាធារណៈ និងបដិសេធលើផ្នែកដទៃទៀតនៃសំណើ នៅដំណាក់កាលនេះ។

## ២. <u>ការចោទប្រកាន់អំពីការខកខានក្នុងការពិចារណាលើអង្គហេតុដែលពុំត្រូវបានចោទប្រកាន់ជាផ្លូវការ</u>

34. នៅពេលនេះ អង្គបុរេជំនុំជម្រះសូមងាកទៅពិនិត្យមើលការអះអាងដែលថា វាមិនត្រឹមត្រូវតាមផ្លូវច្បាប់ក្នុងការសម្រេចថា អង្គហេតុដែលពុំត្រូវបាន "ចោទប្រកាន់" មិនអាចបញ្ជូនទៅជំនុំជម្រះបានទេ ហេតុដូច្នេះ ចៅក្រមមានកំហុសនៅក្នុងការបដិសេធសំណើសុំស៊ើបអង្កេតដោយផ្អែកលើមូលដ្ឋានថា អង្គហេតុដូចបានចោទប្រកាន់ពុំត្រូវបានចោទប្រកាន់ជាផ្លូវការ[60]។

### *លក្ខខណ្ឌតម្រូវឱ្យចោទប្រកាន់អង្គហេតុជាផ្លូវការនៅមុនពេលបញ្ជូនទៅជំនុំជម្រះ*

35. នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ មានតែអង្គហេតុដែលត្រូវបានចោទប្រកាន់ជាមុនតែប៉ុណ្ណោះទើបអាចយកមកពិចារណាចោទប្រកាន់បញ្ជូនទៅជំនុំជម្រះបាន។ នៅក្នុងសេចក្តីសម្រេចនៃសំណុំរឿង ០០២ ដែលសហព្រះរាជអាជ្ញាអន្តរជាតិយោង[61] សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់យ៉ាងច្បាស់ថា សហចៅក្រមស៊ើបអង្កេត "មិនអាចនឹងធ្វើការបញ្ជូនបុគ្គលណាមួយទៅជំនុំជម្រះចំពោះអង្គ

---

[60] *សូមមើល ខទ.* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២ កថាខណ្ឌ ៩-១១។

[61] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២, ១៧។



TRIAL CHAMBER CHAMBRE C.C.C. C.E.T.C.

ហេតុណាដែលបុគ្គលនោះមិនត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ជាមុននោះទេ*"[62] ហើយសហចៅក្រមស៊ើបអង្កេតនឹងធ្វើសេចក្ដីសម្រេច នៅក្នុងដីកាដំណោះស្រាយអំពីអង្គហេតុទាំងអស់ដែលសហចៅក្រមស៊ើបអង្កេតបានទទួលត្រឹមត្រូវ "ដោយអាចនឹងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង *បន្ទាប់ពីដាក់ពួកគេឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ* ឬ ចេញដីកាលើកលែងចោទប្រកាន់ [...]"[63]។ ការសម្រេចនេះផ្ទុះបញ្ចាំងបទប្បញ្ញត្តិជាក់លាក់នៃវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ដែលយោងតាមបទប្បញ្ញត្តិនេះដីកាដំណោះស្រាយអាចចោទប្រកាន់ "*ជន ត្រូវចោទ*"[64] បញ្ជូនទៅជំនុំជម្រះ ហើយនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងបារាំង ដែលយោងតាមនីតិវិធីទាំងនេះ បុគ្គលដែលត្រូវបានចោទប្រកាន់ជាមុនទើបអាចត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំ ជម្រះបាន[65]។

36. ហេតុផលជាក់លាក់ដែលកំណត់ដំណើរការចោទប្រកាន់ជាលក្ខខណ្ឌតម្រូវ សម្រាប់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះនាពេលបន្តបន្ទាប់ គឺដើម្បីការពារសិទ្ធិរបស់ជនសង្ស័យ ឬ ជនជាប់ចោទ។ តាមរយៈដំណើរការចោទប្រកាន់នេះ ពុំមែនតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឡើយ ដែលបុគ្គលម្នាក់មិនត្រឹមតែទទួលបានការជូនដំណឹងប៉ុណ្ណោះទេ ប៉ុន្តែបុគ្គលនេះក៏ត្រូវបានដាក់ឱ្យស្ថិតនៅក្នុងស្ថានភាពមួយត្រូវឆ្លើយតបទៅនឹងការចោទប្រកាន់ និងត្រៀមរៀបចំការការពារខ្លួនផងដែរ ត្រឹមកម្រិតមួយដែលអាចឱ្យបុគ្គលនោះអាចអនុវត្តសិទ្ធិរបស់ខ្លួនបាន[66]។ បន្ទាប់មក ជនត្រូវចោទត្រូវបានជូនដំណឹងជាផ្លូវការអំពីបទចោទប្រឆាំងនឹងខ្លួនទៅតាមលក្ខខណ្ឌតម្រូវនៅក្នុងវិធាន ២១(ឃ) នៃវិធានផ្ទៃក្នុង ហើយចាប់ពីពេលនោះមកអាច

[62] សេចក្ដីសម្រេចលើសំណុំរឿង ០០២ កថាខណ្ឌ ១០ [ការគូសបញ្ជាក់បន្ថែម]។

[63] សេចក្ដីសម្រេចលើសំណុំរឿង ០០២ ផ្នែកសម្រេចសេចក្ដី ទំព័រ ៦ [ការគូសបញ្ជាក់បន្ថែម]។

[64] [ការគូសបញ្ជាក់បន្ថែម]។

[65] *សូមមើល ឧទា.* ព្រឹត្តប័ត្រព្រហ្មទណ្ឌតុលាការកំពូល ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ សំណុំរឿងលេខ 14-84187 (ដែលបានសម្រេចថា អនុលោមតាមមាត្រា ១១៣-៥, ១៧៩, ២០៤ និង ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មានតែបុគ្គលដែលត្រូវបានចោទប្រកាន់ជាមុនប៉ុណ្ណោះទើបអាចត្រូវបានបញ្ជូនទៅជំនុំជម្រះដោយចៅក្រមស៊ើបសួរ និងបញ្ជូនទៅផ្ដន្ទាទោសនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបាន)។

[66] *សូមមើល ឧទា.* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូន [redacted] ទៅជំនុំជម្រះ កថាខណ្ឌ ១៣៨។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក [redacted] ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០ ឯកសារ C22/9/14 កថាខណ្ឌ ២៦។

ដើរតួនាទីសំខាន់នៅក្នុងកិច្ចដំណើរការស៊ើបអង្កេត[67]។ យោងតាមការយល់ឃើញរបស់ស្ថាប័នអយ្យការ ដំណើរការចោទប្រកាន់ក៏បានបញ្ជាក់បំភ្លឺអំពីបទចោទទាំងឡាយដែលត្រូវរក្សាទុកក្នុងចំណោមបទចោទដំបូងៗ។ ករណីដែលថា ចុងបណ្តឹងសាទុក្ខបានលើកនូវទឡ្ហីករណ៍ផ្លូវច្បាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងឡាយនៅគុកលេខ ៨ និងនៅស្រុកបាកាននៅក្នុងអំឡុងពេលស៊ើបសួរ[68] ពុំជួយសម្រាលលក្ខខណ្ឌនីតិវិធីនេះទេ។ នៅចុងក្រោយ ជនសង្ស័យអាចត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះចំពោះតែអង្គហេតុនានាដែលខ្លួនត្រូវបានចោទប្រកាន់ជាផ្លូវការដាច់ដោយឡែកពីកាលៈទេសៈជុំវិញអង្គហេតុទាំងនោះប៉ុណ្ណោះ។

37.ម្យ៉ាងវិញទៀត នៅក្នុងរឿងក្ដីនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វាមិនពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានអំពីការអនុវត្តវិធាន ៦៦ *ស្ទួន* នៃវិធានផ្ទៃក្នុង និងការរំលោភកាតព្វកិច្ចក្នុងការធ្វើសេចក្តីសម្រេចដោយមានសំអាងហេតុលើគ្រប់ការចោទប្រកាន់នោះឡើយ។ នៅក្នុងដំណាក់កាលនេះ វាជាសម្មតិកម្មសុទ្ធសាធក្នុងការប៉ាន់ស្មានអំពីការពិចារណាណាមួយដែលសហចៅក្រមស៊ើបអង្កេតនឹងធ្វើឡើងនៅក្នុងដីកាដំណោះ ស្រាយចំពោះអង្គហេតុនីមួយ ឬ គ្រប់អង្គហេតុដែលសហចៅក្រមស៊ើបអង្កេតទទួលបាន។

38. អង្គបុរេជំនុំជម្រះសូមរំលឹកបន្ថែមទៀតថា បទចោទនៅក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបអង្កេតគឺមានលក្ខណៈបណ្តោះអាសន្នប៉ុណ្ណោះ[69]។ សហចៅក្រមស៊ើបអង្កេតនៅតែទទួលបានគ្រប់អង្គហេតុទាំងអស់នៅឡើយ ហើយអាចកែប្រែបទចោទបានរហូតដល់ពេលចេញដីកាដំណោះស្រាយ។

---

[67] *សូមមើល* សំណុំរឿង ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ("សំណុំរឿង ០០៣") (អ.ប.ជ ២៩) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលដាក់ [redacted] ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីអំពើបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ និងអនុវត្តសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ឯកសារ D174/1/4 ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ [redacted]") កថាខណ្ឌ ១៣។

[68] *សូមមើល ដូចខាងលើ* កថាខណ្ឌ ២២ កថាខណ្ឌ ២៨។

[69] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] កថាខណ្ឌ ២២ *ដែលយោងលើ*សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ កថាខណ្ឌ ១០។

ទោះបីជាសេចក្តីសម្រេចចោទប្រកាន់ជនសង្ស័យធ្វើឡើងដោយ*ភាគីម្ខាង*ក៏ដោយ[70] ក៏ពួកគេមានសិទ្ធិចូលរួមនៅក្នុងការស៊ើបអង្កេតបាន។ ហេតុដូច្នេះ វាអាស្រ័យលើពួកគេជាអ្នកស្នើសុំបទចោទបន្ថែមនៅ ក្នុងទម្រង់ជាសំណើសុំបំពេញកិច្ចស៊ើបសួរនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ស្របតាមរយៈពេលកំណត់ដូចមានចែងនៅក្នុងវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង និងធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធ អនុលោមតាមវិធាន ៧៤(២) នៃវិធានផ្ទៃក្នុងនោះ។

*ការបដិសេធសំណើសុំដោយផ្អែកលើមូលដ្ឋានថា អង្គហេតុទាំងនោះពុំត្រូវបានចោទប្រកាន់ជាផ្លូវការ*

39. អង្គបុរេជំនុំជម្រះសូមរំលឹកឡើងវិញថា អនុលោមតាមវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចស៊ើបអង្កេតលើគ្រប់អង្គហេតុទាំងអស់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[71] ដូចបានពិនិត្យលម្អិតនៅក្នុងផ្នែកខាងក្រោម។ អង្គបុរេជំនុំជម្រះបានកំណត់យ៉ាងច្បាស់បន្ថែមទៀតនូវលក្ខខណ្ឌត្រួតចំនួនពីរដែលត្រូវបំពេញ ដើម្បីអាចឱ្យមានការយល់ព្រមតាមសំណើសុំអនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ពោលគឺ លក្ខខណ្ឌស្តីពីភាពច្បាស់លាស់ និងលក្ខខណ្ឌស្តីពីភាពពាក់ព័ន្ធបឋម[72]។

40. នៅដើមដំបូង អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដើម្បីអាចឱ្យយល់ព្រមតាមសំណើសុំនៅក្នុងការស៊ើបអង្កេតដំណាក់កាលនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិតម្រូវឱ្យបង្ហាញ "កាលៈទេសៈពិសេសតែប៉ុណ្ណោះ ដូចជា មានការបង្ហាញយ៉ាងច្បាស់ថា កិច្ចស៊ើបសួរដែលបានស្នើអាចនាំឱ្យមានភស្តុតាងថ្មីដែលអាចកែប្រែខ្លឹមសារ ឬ បដិសេធភស្តុតាងនៅក្នុងសំណុំរឿង"[73]។ គាត់បាន

[70] សំណុំរឿង ០០៤ (អ.ប.ជ ១៩) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់អ្នកស្រីឱ្យស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ* ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ D239/1/8 កថាខណ្ឌ ១៩ កថាខណ្ឌ ២១។

[71] សេចក្តីសម្រេចក្នុងសំណុំរឿង ០០២ កថាខណ្ឌ ៦ និងលេខយោងជើងទំព័រ ១៖ សំណុំរឿង ០០៣ (អ.ប.ជ ២០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ [redacted] ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D134/1/10 មតិយោបល់របស់ចៅក្រម Beauvallet និង Bwana កថាខណ្ឌ ១៣។

[72] *សូមមើល ខាងលើ* កថាខណ្ឌ ១៧។

[73] ដីកាសម្រេចដែលរងការជំទាស់កថាខណ្ឌ ៣០។



TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

បន្ថែមទៀតថា "សំណើដែលគ្រាន់តែស្នើសុំពង្រីកមូលដ្ឋានភស្តុតាង (ក្នុងករណីដែលមានភស្តុតាងគ្រប់គ្រាន់ហើយទាក់ទងនឹងបញ្ហាណាមួយនោះនឹង [...] ត្រូវបដិសេធ"[74]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ខណៈដំណាក់កាលស៊ើបអង្កេត និងភាពទាន់ពេលវេលាគឺជាកត្តាពាក់ព័ន្ធដែលត្រូវយកមកពិចារណានៅក្នុងការវាយតម្លៃលើសំណើសុំ ដីកាសម្រេចដែលរងការជំទាស់ មានកំហុសដោយសារតម្រូវឱ្យបង្ហាញកាលៈទេសៈពិសេសក្រោយពេលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ហេតុដូច្នេះ វាជាការកំណត់បទដ្ឋានមួយខ្ពស់ជាងការបង្ហាញអំពីភាពពាក់ព័ន្ធ *បឋម*នៃភស្តុតាងដែលបានស្នើសុំ។

41. ទោះបីយ៉ាងណាក៏ដោយអង្គបុរេជំនុំជម្រះពិចារណាឃើញថា សហចៅក្រមស៊ើបអង្កេតពុំមានកំហុសនៅក្នុងការបដិសេធសំណើសុំដោយផ្អែកលើមូលដ្ឋានថា អង្គហេតុពុំត្រូវបានចោទប្រកាន់នោះទេ។ នៅក្នុងរឿងក្តីបច្ចុប្បន្ន នត្ថិភាពនៃការចោទប្រកាន់ត្រូវបកស្រាយថាបានផ្ទុះបញ្ចាំងនត្ថិភាពនៃភស្តុតាងជាក់លាក់ និងស៊ីសង្វាក់គ្នា ក្រោយពេលបញ្ចប់កិច្ចស៊ើបសួរ ដើម្បីគាំទ្រការចោទប្រកាន់ដែលជាបញ្ហាចោទទាំងនោះ។ អង្គបុរេជំនុំជម្រះសូមរម្លឹកអំពីកម្រិតនៃឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងការដឹកនាំការស៊ើបអង្កេត និងនៅក្នុងការវាយតម្លៃលើសំណើសុំបំពេញកិច្ចស៊ើបសួរ[75] ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់សាលាឧទ្ធរណ៍។ ជាពិសេស វាពុំមែនមិនសមហេតុផលសម្រាប់សហចៅក្រមស៊ើបអង្កេត នៅពេលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ក្នុងការបន្ថយ និងកម្រិតបញ្ហាដែលគាត់កំពុងស៊ើបអង្កេត[76] និងក្នុងការ

---

[74] *ដូចខាងលើ*។

[75] *សូមមើល ឧទា.* សេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១២ កថាខណ្ឌ ២៦។

[76] *សូមមើល ឧទា.* សេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១២ កថាខណ្ឌ ៣៥ *ដែលយោងលើ* សំណុំរឿង ០០៤ (អ.ប.ជ ២៤) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើលើកទីប្រាំរបស់ [redacted] សុំបំពេញកិច្ចស៊ើបសួរ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ D260/1/1/3 ("សេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំ") កថាខណ្ឌ ៥៧។ សំណុំរឿង ០០២ (អ.ប.ជ ៤៣) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D313/2/2 កថាខណ្ឌ ២៩។



E.C.C.C * C.E.T.C. TRIAL CHAMBER CHAMBRE PRE

ពិចារណាភស្តុតាងនៅក្នុងសំណុំរឿងដែលគ្រប់គ្រាន់ដើម្បីឱ្យគាត់ជឿជាក់លើបញ្ហាចោទនេះ[77] ដោយពុំបានធ្វើការសម្រេចលើអង្គហេតុឱ្យបានទាន់ពេលវេលានោះឡើយ។

42. យោងតាមហេតុផលខាងលើ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបង្កើតជាកំហុសអង្គហេតុណាមួយដែលនាំឱ្យមោឃៈសេចក្តីសម្រេចនោះទេ។ ក៏ប៉ុន្តែ ការយល់ឃើញនេះសន្មតជាមុនថា សេចក្តីសម្រេចមិនចោទប្រកាន់នោះគឺជាលទ្ធផលនៃការស៊ើបអង្កេតប្រកបដោយយុត្តិធម៌ ហើយអង្គហេតុទាំងឡាយត្រូវបានស៊ើបអង្កេតត្រឹមត្រូវមុនឈានដល់សេចក្តីសន្និដ្ឋាននេះ។

## ៣. ការចោទប្រកាន់អំពីការរំលោភកាតព្វកិច្ចក្នុងការស៊ើបអង្កេតអង្គហេតុទាំងអស់

43. អង្គបុរេជំនុំជម្រះសូមងាកទៅពិនិត្យមើលថាតើសហចៅក្រមស៊ើបអង្កេតបានរំលោភកាតព្វកិច្ចរបស់ខ្លួនក្នុងការស៊ើបអង្កេតអង្គហេតុទាំងអស់ រួមទាំង ការចោទប្រកាន់អំពើហិង្សាផ្លូវភេទនៅគុកលេខ ៨ និងនៅក្នុងស្រុកបាកាន ដូចបានអះអាងដោយសហព្រះរាជអាជ្ញាអន្តរជាតិដែរឬទេ[78]។ មេធាវីការពារក្តីអះអាងថា គ្មានការចង្អុលបញ្ជាក់ណាមួយថា ការចោទប្រកាន់ទាំងនេះត្រូវបានច្រានចោល និងពុំបានស៊ើបអង្កេតនោះទេ[79]។

### *ការចោទប្រកាន់អំពីអំពើហិង្សាផ្លូវភេទនៅគុកលេខ ៨*

44. សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយ ឬ ស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦ នាក់ឡើងវិញ [redacted], [redacted], [redacted], [redacted], [redacted], និង [redacted] ព្រមទាំង [redacted] ហើយនឹង [redacted] ហៅ [redacted], [redacted], [redacted], និង [redacted] ប្រសិនបើពួកគេត្រូវបានស្តាប់ចម្លើយអំពីទិដ្ឋភាពផ្សេង

---

[77] *សូមមើល ឧទា.* សេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំ កថាខណ្ឌ ៥៧ *ដែលយោងលើ* សំណុំរឿង ០០២ (អ.ប.ជ ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការណែនាំឱ្យពិចារណាឡើងវិញលើសំណុំសុំ D153, D172, D173, D174, D178 និង D284 ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ D300/1/7 កថាខណ្ឌ ២៦។

[78] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២២-២៤។

[79] ចម្លើយតប កថាខណ្ឌ ២៩-៣៣។

ទៀតមែននោះ[80]។ គាត់ចង់ស្នើសុំការបញ្ជាក់បំភ្លឺនៅពេលណាដែលការរំលោភសេពសន្ថវៈបានកើតឡើង ថាតើស្ត្រីគោលដៅទាំងនោះត្រូវបានគេបំបែកដែរឬទេ ថាតើមានអំពើហិង្សាផ្លូវភេទប្រឆាំងនឹងអ្នកជម្លៀសមកពីភូមិភាគបូព៌ាដែរឬទេ និងជាទូទៅការកំណត់អត្តសញ្ញាណលើប្រភពនានា[81]។

45. ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិកត់សម្គាល់ដោយសង្ខេបថា ចុងបណ្តឹងសាទុក្ខពុំត្រូវបានចោទប្រកាន់អំពីបទឧក្រិដ្ឋពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទនៅគុកលេខ ៨ ក៏ដោយ[82] វាបង្ហាញច្បាស់ថា យោងតាមការពិនិត្យមើលដីកាសម្រេចដែលរងការជំទាស់ជារួម និងយោងតាមសម្ភារៈដែលប្រមូលបាននៅក្នុងអំឡុងពេលស៊ើបអង្កេត ឧក្រិដ្ឋកម្មបែបនេះត្រូវបានស៊ើបអង្កេតរួចហើយ។ ជាពិសេស សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា "កិច្ចស៊ើបសួរចុងក្រោយបង្អស់ពាក់ព័ន្ធនឹងគុកលេខ ៨ បានធ្វើឡើងនៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥"[83] ហើយគាត់បានពិចារណាថា "ទីតាំងឧក្រិដ្ឋកម្មនេះ រាប់បញ្ចូលទាំង [...] រចនាសម្ព័ន្ធគ្រប់គ្រងពាក់ព័ន្ធនឹងមន្ទីរសន្តិសុខនេះត្រូវបានស៊ើបអង្កេតគ្រប់គ្រាន់រួចហើយ"[84]។ ជាពិសេស គាត់យល់ឃើញថា វាពុំចាំបាច់ព្យាយាមសាជាថ្មីឡើយក្នុងការស្តាប់ចម្លើយ [redacted] ដោយសារបុគ្គលរូបនេះមានជំងឺ និងមានវ័យចំណាស់[85] [redacted] និង [redacted] ដោយសារបញ្ហាពាក់ព័ន្ធនឹងសន្តិសុខមិនមានលក្ខណៈច្បាស់លាស់[86] ឬស្តាប់ចម្លើយ [redacted], [redacted] ដែលពុំត្រូវបានឃុំឃាំងនៅគុកលេខ ៨[87] និង [redacted] ដែលពុំដែលបានទៅជិតមន្ទីរសន្តិសុខទាល់តែសោះ[88]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិជឿជាក់ថា ការស្តាប់ចម្លើយបន្ថែមនឹងមិនផ្លាស់ប្តូរយ៉ាងសំខាន់លើភស្តុតាងដែលមាននៅក្នុងសំណុំរឿងរួច

---

80 សំណើសុំបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ ១១។

81 *ដូចខាងលើ*។

82 ដីកាសម្រេចដែលរងការជំទាស់កថាខណ្ឌ ៤០។

83 ដីកាសម្រេចដែលរងការជំទាស់កថាខណ្ឌ ៣១។

84 ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៤។

85 ដីកាសម្រេចដែលរងការជំទាស់កថាខណ្ឌ ៣៣, ៤៧។

86 ដីកាសម្រេចដែលរងការជំទាស់កថាខណ្ឌ ៣៤។

87 ដីកាសម្រេចដែលរងការជំទាស់កថាខណ្ឌ ៣៩។

88 *ដូចខាងលើ*។



២២ C.C.C. * C.E.T.C. TRIAL CHAMBER CHAMBRE

ហើយនោះឡើយ[89] ហើយបានបញ្ជាក់យ៉ាងច្បាស់ថា បញ្ហាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធគ្រប់គ្រង និង អ្នកជម្លៀសមកពីភូមិភាគបូព៌ាអាចពន្យល់បានដោយភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿង[90]។

46. ម្យ៉ាងវិញទៀត អង្គបុរេជំនុំជម្រះបានពិនិត្យមើលយ៉ាងហ្មត់ចត់លើខ្លឹមសារនៃសំណុំរឿង ពាក់ព័ន្ធនឹងគុកលេខ ៨ ហើយយល់ឃើញថា សំណុំរឿងនេះបង្ហាញថា ការចោទប្រកាន់អំពីអំពើហិង្សាផ្លូវភេទត្រូវបានស៊ើបអង្កេតតាមរយៈសំណួរ និងការសាកសួរបន្តដែលបានដេញដោលដោយអ្នកស៊ើបអង្កេតនៅពេលស្ដាប់ចម្លើយសាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[91]។ បន្ថែមពីនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំ ស្ដាប់ចម្លើយ [redacted] ពុំមានមូលដ្ឋានច្បាស់លាស់ឡើយ ដោយសារប្រភពឯកសារដែលបានយោងដោយសហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ថា បុគ្គលនេះបានទទួលមរណភាពរួចហើយនោះ[92]។

*ការចោទប្រកាន់អំពីអំពើហិង្សាផ្លូវភេទនៅស្រុកបាកាន*

---

[89] ដីកាសម្រេចដែលរងការជំទាស់កថាខណ្ឌ ៣៦។

[90] *ដូចខាងលើ*។

[91] *សូមមើល ឧទា.* កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ D6.1.761 ត្រង់ ERN 00379316។ កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០១២ ឯកសារ D105/9 ត្រង់ ERN 00919439។ កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D219/58 ត្រង់ ERN 01053859-01053862។ កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ D219/265 ត្រង់ ERN 01098463។ កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ D219/279 ត្រង់ ERN 01098536។ កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ D219/340 ត្រង់ ERN 01117706។ កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D219/526 ត្រង់ ERN 01168051-01168052។ កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D219/553 ត្រង់ ERN 01178602។ កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D219/554 ត្រង់ ERN 01178622-01178623។ កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D219/555 ត្រង់ ERN 01178644-01178645។

[92] សំណើសុំបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ ១១ និងលេខយោងជើងទំព័រ ៤៣ *ដែលយោងលើ* បណ្ដឹងរបស់ [redacted] ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ D2.1.85a ត្រង់ ERN 00888105។ *សូមមើលផងដែរ* សេចក្ដីសង្ខេបនៃបណ្ដឹងរបស់ [redacted] ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០០៩ ឯកសារ D2.1.85b ត្រង់ ERN 00461296។

47. សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយបុគ្គលបួនរូបដែលត្រូវបានសួរចម្លើយជាផ្លូវការដោយក្រុមការពារសិទ្ធិមនុស្សកម្ពុជា[93] និងបុគ្គលបីរូបបន្ថែមទៀតដែលសាក្សី [redacted], [redacted] និង [redacted] បានលើកឡើង[94]។ គាត់មានគោលបំណង "ចង់ស្វែងយល់ការដឹងឮអំពីអំពើហិង្សាផ្លូវភេទដែលត្រូវបានប្រព្រឹត្តឡើងដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) និងអ្នកដែលស្ថិតក្រោមការគ្រប់គ្រងរបស់ពួកគេនៅក្នុងស្រុកបាកានក្នុងឆ្នាំ ១៩៧៨ រហូតដល់ចុងបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ" ដោយបានបញ្ជាក់អំពីប្រភព និងកាលៈទេសៈនៃអំពើហិង្សាផ្លូវភេទនៅស្រុកបាកាន ខណៈចុងបណ្តឹងសាទុក្ខជាគណកម្មាធិការភូមិភាគពាយ័ព្យ ទណ្ឌកម្មប្រឆាំងនឹងចារី និងជនរងគ្រោះ និងការដឹងឮរបស់កម្មាភិបាល ប.ក.ក[95]។

48. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតច្រានចោលចំណើសុំដោយផ្អែកលើមូលដ្ឋានថា ចុងបណ្តឹងសាទុក្ខពុំត្រូវបានចោទប្រកាន់ជាផ្លូវការអំពីបទឧក្រិដ្ឋពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទនៅស្រុកបាកាន ហើយបានយោងលើសំអាងហេតុរបស់គាត់ពាក់ព័ន្ធនឹងគុកលេខ ៨[96]។ ទោះបីជាយ៉ាងនេះក្តី អង្គបុរេជំនុំជម្រះពុំទទួលយកការអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរំលោភកាតព្វកិច្ចរបស់គាត់ក្នុងការស៊ើបអង្កេតអង្គហេតុទាំងអស់ដែលគាត់បានទទួលត្រឹមត្រូវនោះឡើយ។

49. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ចំណុចទីមួយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងដល់ភាគីនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦ ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិជឿជាក់ថា មាន "ភស្តុតាងច្បាស់លាក់ និងស៊ីសង្វាក់ថា ការរំលោភសេពសន្ថវៈ [...] អាចត្រូវបានប្រព្រឹត្តប្រឆាំងខ្មែរក្រោម និងស្ត្រីភូមិភាគបូព៌ានៅក្នុងស្រុកបាកាន"[97]។ ដូច្នេះ វាគ្មានមន្ទិលសង្ស័យទេថាគាត់បានស៊ើបអង្កេតការចោទប្រកាន់ទាំងអស់អំពីអំពើហិង្សាផ្លូវភេទនៅស្រុកបាកាន និងកាលៈទេសៈជុំវិញនោះរហូតអាចឱ្យគាត់ជឿជាក់លើបញ្ហាចោទនោះ។ ជាការពិតណាស់ ការពិនិត្យមើលខ្លឹមសារនៃសំណុំរឿងពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅក្នុងស្រុកបាកាន បញ្ជាក់ថា

[93] សំណើសុំបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ ១៨។

[94] សំណើសុំបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ ១៩-២២។

[95] សំណើសុំបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ ១៨។

[96] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៥០។

[97] សំណើសុំយោបល់ កថាខណ្ឌ ៣។



PRE-TRIAL CHAMBER CHAMBRE * E.C.C.C * C.E.T.C

ការចោទប្រកាន់អំពីអំពើហិង្សាផ្លូវភេទត្រូវបានស៊ើបអង្កេតតាមរយៈសំណួរ និងការសាកសួរបន្ត ដែលបានដេញដោលដោយអ្នកស៊ើបអង្កេត[98] ហើយតាមរយៈការដាក់ឯកសារផ្សេងទៀតនៅក្នុងសំណុំរឿង[99]។ ដោយពិនិត្យឃើញថា សេចក្តីសម្រេចត្រូវយកមកពិនិត្យជារួម អង្គបុរេជំនុំជម្រះយល់ឃើញថា វាមិនមែនមិនសមហេតុផលនោះឡើយដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាថាភស្តុតាងនៃអំពើហិង្សាផ្លូវភេទមានលក្ខណៈគ្រប់គ្រាន់នៅដំណាក់កាលនេះ ហើយច្រានចោលសំណើសុំពង្រីកមូលដ្ឋានភស្តុតាងនោះ។ ជាពិសេស វានឹងជាការប៉ាន់ស្មានសុទ្ធសាធ

[98] *សូមមើល ឧទា.* កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D65.1.56, at ERN 00327162-00327163។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារ D6.1.142 ត្រង់ ERN 00279253។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D6.1.757 ត្រង់ ERN 00387502។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D6.1.758 ត្រង់ ERN 00387496។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ D6.1.759 ត្រង់ ERN 00388621។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ D6.1.845 ត្រង់ ERN 00402823-00402824។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D118/124 ត្រង់ ERN 00975898។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D118/125 ត្រង់ ERN 00976594-00976595។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D118/127 ត្រង់ ERN 00979977-00979978។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០១៤ D118/226 ត្រង់ ERN 01055755។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D118/254 ត្រង់ ERN 01025237។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D118/289 ត្រង់ ERN 01079690-01079691។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/170 ត្រង់ ERN 01072582-01072583។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D219/221 ត្រង់ ERN 01104769-01104770។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D219/224 ត្រង់ ERN 01088613-01088614។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ D219/279 ត្រង់ ERN 01098538។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ D219/338 ត្រង់ ERN 01117693-01117694។ កំណត់ហេតុនៃការស្តាប់ចម្លើយ [redacted] ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ D219/639 ត្រង់ ERN 01198194-01198195។

[99] *សូមមើល ឧទា.* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted] ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D5/946/1 ត្រង់ ERN 00981390-00981391។ កំណត់ហេតុនៃការស៊ើបអង្កេត ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ D219/738 ដោយភ្ជាប់ជាមួយនឹងកម្រងសំណួររបស់ក្រុមការពារសិទ្ធិមនុស្សកម្ពុជា D219/738.1.9, D219/738.1.12, D219/738.1.13, D219/738.1.15, D219/738.1.23, D219/738.1.24, D219/738.1.26, D219/738.1.27, D219/738.1.28, និង D219/738.1.31។

ក្នុងការជឿជាក់ថា ស្វាមីរបស់ [redacted] ដែលសហព្រះរាជអាជ្ញាស្នើសុំស្ដាប់ចម្លើយ អាចបង្ហាញភ័ស្ដុតាងពាក់ព័ន្ធផ្សេងទៀត ដោយសារសាក្សីរូបនេះបានបញ្ជាក់យ៉ាងច្បាស់ថា គាត់បានឮអំពីការរំលោភសេពសន្ថវៈតែពីស្ត្រីម្នាក់ទៀតឈ្មោះ [redacted] ប៉ុណ្ណោះ[100]។

50. ចំណុចទីពីរ ទោះបីជាសហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ "ភ័ស្តុតាងមិនគ្រប់គ្រាន់ដែល [ចុងបណ្ដឹងសាទុក្ខ] អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម"[101]យ៉ាងណាក៏ដោយ ក៏គាត់បានសម្រេចនៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ បន្តនីតិវិធីស៊ើបអង្កេតពាក់ព័ន្ធនឹងការចោទប្រកាន់អំពីអំពើហិង្សាផ្លូវភេទនៅក្នុងស្រុកបាកាន[102]។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅចន្លោះកាលបរិច្ឆេទនេះ និងសេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរនៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ ចម្លើយសាក្សីបន្ថែមមួយចំនួនត្រូវបានកត់ត្រាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវនៅក្នុងស្រុកបាកាន និងតំបន់ ២[103]។ ហេតុដូច្នេះ គ្មានសញ្ញាណណាមួយបង្ហាញថា សហចៅក្រមស៊ើបអង្កេតមិនបានពិចារណា និងស៊ើបអង្កេត ការចោទប្រកាន់បទឧក្រិដ្ឋអំពើហិង្សាផ្លូវភេទនៅក្នុងស្រុកបាកាននោះឡើយ។

51. អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចចោទប្រកាន់ចុងបណ្ដឹងសាទុក្ខពីបទប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅតាមទីតាំងឧក្រិដ្ឋកម្មបន្ថែមចំនួនប្រាំនៅក្នុងស្រុកបាកាន[104] ដោយបានរកឃើញ "ភ័ស្តុតាងយ៉ាងច្បាស់ និងស៊ីសង្វាក់គ្នា [ថា ចុងបណ្ដឹងសាទុក្ខ] អាចទទួលខុសត្រូវព្រហ្មទណ្ឌ" ជាពិសេស ក្នុងតួនាទីរបស់គាត់ជាអនុលេខាភូមិភាគពាយ័ព្យ តាមរយៈទម្រង់នៃការ

---

[100] កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ D219/279 ត្រង់ ERN 01098538។

[101] សំណើសុំយោបល់ កថាខណ្ឌ ៣។

[102] សេចក្ដីជូនដំណឹងអំពីការមិនបន្តបណ្ដោះអាសន្ន កថាខណ្ឌ ៣២។

[103] *សូមមើល ឧទា.* កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ D219/842; កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ D219/843។ កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D219/861។ កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារ D219/921។ កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted] ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារ D219/936។

[104] សេចក្ដីជូនដំណឹងអំពីបទចោទដែលបានកែប្រែ ទំព័រ ២, ៥, ៩។

ទទួលខុសត្រូវលើការប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈសហឧក្រិដ្ឋកម្មរួម ការទទួលខុសត្រូវរបស់ថ្នាក់លើ ការរៀបចំផែនការ ការបញ្ជា និងការញុះញង់[105]។ ការទទួលខុសត្រូវរបស់គាត់លើការប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈសហឧក្រិដ្ឋកម្មរួមនៅតាមទីតាំងជាក់លាក់នៅក្នុងស្រុកបាកានត្រូវបានកម្រិតត្រឹមការអនុវត្តបញ្ជីរៀបរាប់គោលនយោបាយ ប.ក.ក[106] និងការអនុវត្តផែនការលុបបំបាត់ខ្មែរក្រោម[107]។

52. ប្រសិនបើសហព្រះរាជអាជ្ញាអន្តរជាតិមានបំណងចង់បញ្ជាក់បំភ្លឺនៅមុនពេលដាក់សេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួនអំពីមន្ទិលសង្ស័យថា ហេតុអ្វីបទឧក្រិដ្ឋនៃអំពើហិង្សាផ្លូវភេទពុំត្រូវបានចោទប្រកាន់ជាក់លាក់នៅក្នុងស្រុកបាកាននោះ សហព្រះរាជអាជ្ញាអន្តរជាតិគួរស្នើសុំបន្ថែមបទចោទក្នុងទម្រង់ជាសំណើសុំបំពេញកិច្ចស៊ើបសួរទៅហើយ ជាជាងត្រឹមតែស្នើសុំពង្រីកមូលដ្ឋានភ័ស្តុតាង។

53. ដោយពិចារណាទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើនេះ អង្គបុរេជំនុំជម្រះមិនអាចរកឃើញនូវការខកខានណាមួយក្នុងការស៊ើបអង្កេតការចោទប្រកាន់អំពើហិង្សាផ្លូវភេទនៅគុកលេខ ៨ និងនៅក្នុងស្រុកបាកាននោះឡើយ ហើយអង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធីនេះ និងដោយសារ សហចៅក្រមស៊ើបអង្កេតអន្តរជាតិដឹងច្បាស់អំពីសំណុំរឿងហើយនោះ វាជាឆន្ទានុសិទ្ធិដ៏ត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម ដោយសារវាពុំនាំដល់ការបញ្ជាក់ការពិតនោះឡើយ។

**យោងតាមសំអាងហេតុទាំងនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទៈ**

- **ច្រានចោល** ទុកជាមោឃៈនូវសំណើសុំឱ្យសម្រេចលើបណ្តឹងឧទ្ធរណ៍នៅមុនពេលចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ។

[105] សេចក្តីជូនដំណឹងអំពីបទចោទដែលបានកែប្រែ ទំព័រ ២, ៥, ៩, ១៥-១៦។

[106] សេចក្តីជូនដំណឹងអំពីបទចោទដែលបានកែប្រែទំព័រ ១៥ (រួមទាំងការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន ការដាក់បទបញ្ញាលើអាពាហ៍ពិពាហ៍ ការកសាង "សមាសភាពមិនល្អ" តាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង និងពលកម្មដោយបង្ខំ និងការសម្លាប់ "ខ្មាំង" និងការកំណត់គោលដៅកម្មាភិបាលភូមិភាគពាយ័ព្យ និងអតីតមន្ត្រីរាជការនៃរបបសាធារណរដ្ឋខ្មែរ)។

[107] សេចក្តីជូនដំណឹងអំពីបទចោទដែលបានកែប្រែទំព័រ ១៥-១៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

- **ទទួលយក** ផ្នែកខ្លះនៃសំណើសុំឱ្យដាក់បណ្តឹងឧទ្ធរណ៍នេះជាសាធារណៈ។

- **ច្រានចោល** ផ្នែកនៅសេសសល់នៃបណ្តឹងឧទ្ធរណ៍។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**